**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០៨៦/១៧..........ក.ប/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឲ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៧

**យោង ៖** - លិខិតលេខ ៤៨៧ មស.ក្រ.ខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

- លិខិតលេខ ៩៦៣ មស.ក្រ.ខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ ឲ្យបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១៧ នេះត្រូវការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល(ក្របខ័ណ្ឌប្រភេទ "ក") ចំនួន **២៨**កន្លែង ដោយបែងចែកទៅតាមអង្គភាពដូចខាងក្រោម ៖

| ល.រ | អង្គភាពជ្រើសរើស | ចំនួន | ល.រ | អង្គភាពជ្រើសរើស | ចំនួន |
|---|---|---|---|---|---|
| ១ | ទីស្តីការក្រសួង | **៦** | ៩ | មន្ទីរ កប ខេត្តមណ្ឌលគិរី | **២** |
| ២ | មន្ទីរ កប ខេត្តកំពង់ឆ្នាំង | **១** | ១០ | មន្ទីរ កប ខេត្តរតនគិរី | **២** |
| ៣ | មន្ទីរ កប ខេត្តកំពង់ចាម | **១** | ១១ | មន្ទីរ កប ខេត្តស្ទឹងត្រែង | **១** |
| ៤ | មន្ទីរ កប ខេត្តត្បូងឃ្មុំ | **២** | ១២ | មន្ទីរ កប ខេត្តព្រះវិហារ | **២** |
| ៥ | មន្ទីរ កប ខេត្តព្រៃវែង | **១** | ១៣ | មន្ទីរ កប ខេត្តឧត្តរមានជ័យ | **២** |
| ៦ | មន្ទីរ កប ខេត្តកំពង់ធំ | **១** | ១៤ | មន្ទីរ កប ខេត្តកែប | **១** |
| ៧ | មន្ទីរ កប ខេត្តពោធិ៍សាត់ | **១** | ១៥ | មន្ទីរ កប ខេត្តកោះកុង | **១** |
| ៨ | មន្ទីរ កប ខេត្តក្រចេះ | **២** | ១៦ | មន្ទីរ កប ខេត្តប៉ៃលិន | **២** |
| **សរុប ២៨** (កន្លែង) | | | | | |

### ១-កម្រិតសញ្ញាបត្រ និងលក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- សញ្ញាបត្រយ៉ាងទាបបំផុតត្រឹមកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល
- បេក្ខជនជាមន្ត្រីរាជការ និងបេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីបណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត៣៥ឆ្នាំ
- បេក្ខជនជាមន្ត្រីរាជការត្រូវមានលិខិតអនុញ្ញាតឲ្យប្រឡងពីប្រធានអង្គភាព និងត្រូវអនុញ្ញាតឲ្យផ្ទេរក្របខ័ណ្ឌ

ឬផ្លាស់កន្លែងធ្វើការនៅពេលប្រកាសលទ្ធផលប្រឡងជាប់ជាស្ថាពរ

- បេក្ខជនជាមន្ត្រីរាជការនឹងត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែតួនាទី ឬមុខតំណែងមិនត្រូវបានរក្សានោះទេ
- ក្រសួងនឹងទទួលយកជនពិការចំនួន ០១រូប ដោយស្វ័យប្រវត្តិក្នុងចំណោមបេក្ខជនពិការដែលបានប្រឡង ហើយបានទទួលពិន្ទុខ្ពស់ជាងគេ
- ពេលមកដាក់ពាក្យសុំប្រឡង បេក្ខជនទាំងពីរភេទត្រូវនាំមកជាមួយនូវសញ្ញាបត្រច្បាប់ដើមដើម្បីបង្ហាញដល់មន្ត្រីទទួលខុសត្រូវ
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយនៃពិន្ទុសរុប១០០% ចំពោះ ៖

១/ បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា......................................................................................បន្ថែម៥ពិន្ទុ

២/ បេក្ខជនជាស្ត្រី.............................................................................................................បន្ថែម២ពិន្ទុ

ការបន្ថែមនេះ ផ្តល់ជូនតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយលក្ខខណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខណ្ឌដែលបេក្ខជនមាន ។

## ២-វិញ្ញាសា និងថេរវេលាប្រឡង

- ចំណេះដឹងទូទៅពាក់ព័ន្ធ រដ្ឋបាល និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.......................................................................................................................................................រយៈពេល ២ម៉ោង០០នាទី (មេគុណ៣)
- ភាសាអង់គ្លេស(QCM)...........................................................................រយៈពេល ១ម៉ោង៣០នាទី (មេគុណ១)

❖ <u>វិញ្ញាសាផ្ទាល់មាត់៖</u> ក្រសួងនឹងជូនដំណឹងនាពេលក្រោយ សម្រាប់បេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរ ។

❖ <u>បញ្ជាក់៖</u> បេក្ខជនទាំងពីរភេទ ត្រូវអនុវត្តតាមការកំណត់វិញ្ញាសាប្រឡងខាងលើ ដោយមិនអាចតវ៉ានៅពេលប្រឡង ដើម្បីឲ្យមានការកែសម្រួលតាមជំនាញរបស់ខ្លួនឡើយ ។

## ៣-កាលបរិច្ឆេទលក់ពាក្យ-ទទួលពាក្យ និងឈប់ទទួលពាក្យ

- កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះតទៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៧:៣០-១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០-១៧:០០នាទី ។
- កាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃទី២៨ ខែកក្កដា **ឆ្នាំ២០១៧** វេលាម៉ោង៥:០០នាទីល្ងាច

## ៤-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង

- មណ្ឌលប្រឡងនឹងបិទផ្សាយនៅទីស្តីការក្រសួង នាថ្ងៃទី០៧ **ខែសីហា ឆ្នាំ២០១៧**
- កាលបរិច្ឆេទប្រឡងថ្ងៃទី១១ **ខែសីហា ឆ្នាំ២០១៧**

## ៥-សំណុំលិខិតចុះឈ្មោះប្រឡង

- ពាក្យសុំចុះឈ្មោះប្រឡង ..........................................................................................ចំនួន ០១ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រ ឬអនុបណ្ឌិត ឬបណ្ឌិត ឬសញ្ញាបត្រដែលមានតម្លៃស្មើដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី ..........................ចំនួន ០១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦.......................................................................ចំនួន ០១ច្បាប់
- សលាកបត្រឯកត្តជន................................................................................................ចំនួន ០១ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង.................................................................................ចំនួន ០១ច្បាប់
- បង្កាន់ដៃបង់សិទ្ធិប្រឡង .......................................................................................ចំនួន ០១ច្បាប់
- រូបថតថ្មី ៤x៦ ថតចំពីមុខគ្មានពាក់វ៉ែនតា ឬមួក ....................................................ចំនួន០២សន្លឹក
- លិខិតថ្កោលទោស(ក្រោយពេលប្រឡងជាប់ជាស្ថាពរ) ...............................................ចំនួន ០២ច្បាប់
- លិខិតពិនិត្យកាយសម្បទា(ក្រោយពេលប្រឡងជាប់ជាស្ថាពរ).....................................ចំនួន ០២ច្បាប់

- លិខិតអនុញ្ញាតឲ្យប្រឡងពីប្រធានអង្គភាពដែលកំពុងបម្រើការងារ ................................ចំនួន ០១ច្បាប់
- ប្រកាសស្តីពីការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០១៧ សម្រាប់បេក្ខជន ជាមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ............................ចំនួន០១ច្បាប់

**៦-កំណត់សំគាល់**

- បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡងដោយដៃ ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ និងមកដាក់ពាក្យដោយផ្ទាល់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច "៥" ។
- កន្លែងទំនាក់ទំនងផ្តល់ពាក្យ និងទទួលពាក្យប្រឡង ៖

  ក/ សម្រាប់ទីស្តីការក្រសួង នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក *អាសយដ្ឋាន អគារលេខ៣ មហាវិថី សហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក (ទូរស័ព្ទ ០២៣ ៨៨៤ ៣៧៥)* ជាប់វិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

  ខ/ គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដែលត្រូវជ្រើសរើស ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ ដែលមានបំណងចង់ដាក់ពាក្យសុំប្រឡង មេត្តាជ្រាប និងអនុវត្តតាមការគួរ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពចំណុះក្រសួង "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ